ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ
លេខ.........................................

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែតុលា ឆ្នាំ២០២២

**ក-អំពីកម្លាំង៖**

សរុបរួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

**ខ-សកម្មភាព និងលទ្ធផលការងារ**

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

<u>សកម្មភាពក្នុងស្រុក</u>

- **ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង និង លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុម ជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញ ចូលរួមកិច្ចប្រជុំពិភាក្សារៀបចំសិក្ខាសាលាជាតិប្រមូលធាតុចូលសម្រាប់ផែនការជាតិបន្តរបស់ គ.ជ.ប.ជ ក្រោមការដឹកនាំរបស់ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ មានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ លោកជំទាវឯកឧត្តម អគ្គលេខាធិការរង ទទួលបន្ទុកការងាររដ្ឋបាល ហិរញ្ញវត្ថុ ប្រធានក្រុមជំនួយកិច្ចការជួយជនរងគ្រោះប្រធាន និងសហការីអង្គការវីនរ៉ក់ អន្តរជាតិ (Winrock International) តំណាងពីអង្គការអាស៊ានអាក់ (ASIAN-ACT) តំណាងពីអង្គការអោយ អូ អឹម កម្ពុជា (IOM)។

- **ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ និងលោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី «កិច្ចបង្ការការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ តាមប្រព័ន្ធអនឡាញ និងយន្តការរាយការណ៍ អំពីរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ CSAM» ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលមានរយៈពេល០១ថ្ងៃ នៅសណ្ឋាគារ Hyatt។ សិក្ខាសាលានេះរៀបចំឡើងក្រោមកិច្ចសហការរវាង គ.ជ.ប.ជ និងអង្គការ APLE ដែលមានគោលបំណង៖ គឺដើម្បីបង្កើនការយល់ដឹង ស៊ីជម្រៅអំពីហានិភ័យ និងគ្រោះថ្នាក់ នៃប្រព័ន្ធអនឡាញចំពោះកុមារ ទម្រង់នៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ លើប្រព័ន្ធអនឡាញ

(OCSEA) វិធានសុវត្ថិភាព របៀបរាយការណ៍ និងយន្តការបង្ការ ក៏ដូចជាដើម្បីប្រមូលធាតុចូល និងអនុសាសន៍ ដើម្បីបំពេញកង្វះក្របខណ្ឌច្បាប់ សម្រាប់ក្រុមហ៊ុនឯកជន និងអ្នកផ្តល់សេវាអ៊ិនធឺណិត ឬសេវាអេឡិចត្រូនិក ក្នុងការចូលរួមដោះស្រាយ ហានិភ័យតាមអនឡាញ ការតាមដាននិងរាយការណ៍ មាតិកាខុសច្បាប់ ការច្រោះ និងបិទខ្ទប់មាតិកាដែលមិនសមរម្យសម្រាប់កុមារ និងការសហការជាមួយអ្នកអនុវត្តច្បាប់។ សមាសភាព អញ្ជើញចូលរួមសិក្ខាសាលាសរុបចំនួន ៦៥នាក់ (ស្រី ២១នាក់) ដែលជាតំណាងមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗ។

- **ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញជាមួយ UNWOMEN ដែលបានធ្វើការបង្ហាញអំពីគម្រោងវគ្គ ខ្លីចំនួនក្នុងរយៈពេលមួយឆ្នាំរបស់ខ្លួនគិតចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ខែ កុម្ភៈ ឆ្នាំ២០២៣ ដែលមាន គោលដៅទៅលើខេត្តចំនួន៤ គឺខេត្តសៀមរាប បន្ទាយមានជ័យ បាត់ដំបង និងឧត្តរមានជ័យ ដែលបានផ្តោត ទៅលើផលប៉ះពាល់ពីជំងឺកូវីត-១៩ អំពើហឹង្សា និងបញ្ហាយេនឌ័រ ។ ក្នុងកិច្ចប្រជុំ លោកជំទាវក៏បានស្នើសុំវគ្គ សម្រាប់មណ្ឌល និងមន្ត្រីជួរមុខនូវវគ្គយេនឌ័រ និងអំពើហឹង្សា និងក្រមសីលធម៌ក្នុងការប្រឹក្សា ដោយយក ទីតាំងមណ្ឌលជាគោល។

- **ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង និងលោកឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុមជំនួយកិច្ចការ និងលោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ បានអញ្ជើញ ចូលរួមក្នុងសិក្ខាសាលាស្តីពី "សមភាពយេនឌ័រ ពិការភាព និងបរិយាប័ន្នសង្គម សិទ្ធិជនរងគ្រោះ និងការតាមដាន ការវាយតម្លៃ និងការរៀនសូត្រ" ដែលបានរៀបចំឡើងដោយ ASEAN-ACT។ ដោយទទួលបានការចាត់តាំង លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ តំណាងឱ្យ គ.ជ.ប.ជ បានធ្វើបទបង្ហាញជូនដល់អង្គសិក្ខាសាលាស្តីពីផែនការយុទ្ធសាស្រ្តជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្សរយៈពេល ៥ឆ្នាំផងដែរ។

- **ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពី "សំណើសុំរាជរដ្ឋាភិបាលកម្ពុជាផ្តល់ការបំភ្លឺអំពីករណីជួញដូរមនុស្សនៅកម្ពុជា" ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ អញ្ជើញចូលរួមមាន ឯកឧត្តម នាយឧត្តមសេនីយ៍ កែវ វណ្ណថន អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ឯកឧត្តម ឧត្តមសេនីយ៍ឯក ខៀវ ចាន់ប៉ា អគ្គលេខាធិការរង គ.ជ.ប.ជ ឯកឧត្តម សួង សង្ហារិទ្ធី អគ្គនាយករង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម ជ័យ រដ្ឋា អគ្គនាយករង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លោកស្រី សុន សុខាលីនដា អគ្គនាយករង ក្រសួងយុត្តិធម៌ លោកស្រី ឧត្តមសេនីយ៍ទោ ស៊ឹម ផាណុំ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ លោកស្រី សុភា កន្និដ្ឋា អនុប្រធាននាយកដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លោកប្រធានលេខាធិការរដ្ឋបាលសរុប ប្រធាន អនុប្រធាន ក្រុមជំនួយកិច្ចការទាំង៦ (គ.ជ.ប.ជ) លោក លោកស្រីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ២២រូប (ស្រី៤ រូប)។

- **ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ទោ ថោង សុវត្ថិបានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាជាមួយអង្គការដៃគូ ដើម្បីត្រៀមរៀបចំសិក្ខាសាលាពិនិត្យផែនការជាតិ៥ឆ្នាំ (២០១៩-២០២៣) ពាក់កណ្តាលអាណត្តិ ដែលដឹកនាំដោយលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ គោលបំណងនៃកិច្ចប្រជុំគឺដើម្បីកំណត់ការងារ និងការទទួលខុសត្រូវរបស់អង្គការដៃគូ ក្នុងការសម្របសម្រួលក្រុមពិភាក្សាក្នុងសិក្ខាសាលាពិនិត្យផែនការជាតិពាក់កណ្តាលអាណត្តិ។ សមាសភាពចូលរួមមានអង្គការដៃគូមួយចំនួនដូចជា ASEAN-ACT, Winrok International, IOM, IJM, Caritas Swiss, ERIKS, និង UNFPA រួមទាំងលោកជំទាវ ឯកឧត្តម អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន អនុប្រធាន លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ២៧រូប។

- **ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំតាមប្រព័ន្ធអនឡាញស្តីពី "កុមាររងផលប៉ះពាល់ដោយទេសន្តរប្រវេស្តន៍ ដែលបានធ្វើការសិក្សាស្រាវជ្រាវកន្លងមកនៅខេត្តបាត់ដំបង" ដែលបានរៀបចំឡើងដោយអង្គការ យូនីសេហ្វ។ ក្នុងកិច្ច ប្រជុំនោះ អ្នកស្រាវជ្រាវបានធ្វើកិច្ចប្រជុំបង្ហាញពីលទ្ធផលនៃការសិក្សា និងប្រមូលធាតុចូលតាមអនឡាញ ជាមួយអ្នកពាក់ព័ន្ធផ្សេងៗ។

- **ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង និងលោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញ ចូលរួមក្នុងកម្មវិធីធ្វើបទបង្ហាញរបស់អង្គការ IJM និងកិច្ចប្រជុំក្រុមការងារបច្ចេកទេស (ក្រុមស្ម័គ្រចិត្ត) សម្របសម្រួលដើម្បីត្រៀមរៀបចំសិក្ខាសាលាស្តីពី "ការបង្កើតផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស នៃផែនការយុទ្ធសាស្ត្រជាតិ (2019 - 2023)" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលរៀបចំឡើងតាមប្រព័ន្ធអនឡាញ ហ្សូម និងមានការចូលរួមដោយផ្ទាល់ពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកប្រធាន លោក លោកស្រី អនុប្រធាន ក្រុមជំនួយកិច្ចការទាំង៦ លោក លោកស្រីតំណាងអង្គការ IJM តំណាងអង្គការ Winrock ព្រមទាំងមានការចូលរួមតាមប្រព័ន្ធអនឡាញហ្សូម មានតំណាងអង្គការ ASEAN-ACT, Caritas Swiss, IOM, Cambodia-ACT ដែលមានវត្តមានសរុបចំនួន 20រូប។

**ខ.២-ការងារចងក្រងព័ត៌មានតាមគេហទំព័រសារព័ត៌មាននានា** (មានឆ្នាប់ក្នុងឧបសម្ព័ន្ធ)

- <u>គ្រោះថ្នាក់ ឬហានិភ័យការងារក្នុងប្រទេសគោលដៅ</u>
  - ឧបទ្ទវហេតុ ០០ នាក់
  - ពលករសរុប ០០ នាក់
- <u>ប្រព្រឹត្តបទល្មើសនៅនឹងកន្លែង</u>
  - ចាប់ខ្លួន ០០ នាក់
  - ពលករសរុប ០០ នាក់

- <u>ពលកររួចទោសពីពន្ធនាគារ</u>
    - ពលករសរុប ០០ នាក់
- <u>ពលករចំណាកស្រុកខុសច្បាប់</u>
    - បញ្ជូនត្រឡប់ ០០ នាក់
    - ចាប់ខ្លួន ០០ នាក់
    - ពលករសរុប ០០ នាក់

គ-ទិសដៅបន្ត

- បណ្តុះបណ្តាលជំនាញមូលដ្ឋានបច្ចេកទេសសរសេរប្រូក្រាមដល់ក្រុមការងារព័ត៌មានវិទ្យាថ្មី
- បណ្តុះបណ្តាលគ្រូបង្គោលនៅមណ្ឌលទទួលពលករកំរៀង

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ**